# ផែនការសកម្មភាព ៥ឆ្នាំ
# កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០១៨-២០២២)

## I. គោលដៅអភិវឌ្ឍន៍

១. ផែនការសកម្មភាពនេះត្រូវបានរៀបចំឡើងស្របតាមឯកសារនានារួមទាំង សេចក្តីថ្លែងការណ៍ទីក្រុងសានយ៉ា ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី១ ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃបណ្តាប្រទេសក្នុងអនុតំបន់ លើកកម្ពស់សុខុមាលភាពរបស់ប្រជាជន កាត់បន្ថយគម្លាតអភិវឌ្ឍន៍ក្នុងតំបន់ និងកសាងសហគមន៍មួយដែលរួមអនាគតគ្នាប្រកបដោយសុខសន្តិភាព និងវិបុលភាពក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង។ តាមរយៈសហថាមភាពជាមួយគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវរបស់ចិន ទស្សនវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ ផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងទស្សនវិស័យនៃយន្តការកិច្ចសហប្រតិបត្តិការអនុតំបន់មេគង្គដទៃទៀត កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងកំពុងក្លាយខ្លួនទៅជាយន្តការកិច្ចសហប្រតិបត្តិការអនុតំបន់ថ្មីមួយ ដែលមានលក្ខណៈពិសេសដោយឡែក ដែលត្រូវជំរុញគាំទ្រដោយភាពរឹងមាំផ្ទៃក្នុង និងត្រូវជំរុញទឹកចិត្តដោយកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដែលនឹងគាំទ្រដល់ការកសាងសហគមន៍អាស៊ាន និងដំណើរការសមាហរណកម្មតំបន់ ព្រមទាំងជំរុញការអនុវត្តរបៀបវារៈអង្គការសហប្រជាជាតិឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

## II. គោលការណ៍គ្រឹះ

២. ផែនការសកម្មភាពនេះនឹងគិតគូរពីតម្រូវការអភិវឌ្ឍរបស់ប្រទេសជាសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងទាំងប្រាំមួយ(០៦)និងដំណើរការសមាហរណកម្មតំបន់ ឆ្លុះបញ្ចាំងពីក្របខ័ណ្ឌដែលត្រូវបានបង្កើតឡើងនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងសានយ៉ា ដែលគូសបញ្ជាក់អំពីមគ្គុទេសរបស់ថ្នាក់ដឹកនាំកិច្ចសហប្រតិបត្តិការគ្រប់វិស័យ និងការចូលរួមយ៉ាងទូលំទូលាយ ដោយឈរលើការតម្រង់ទិសដោយរដ្ឋាភិបាល ការចូលរួមចម្រុះ និងទម្រង់យន្តការដែលយកគម្រោងជាមូលដ្ឋាន ដើម្បីបន្តស្វែងរកទម្រង់គំរូនៃកិច្ចសហ-ប្រតិបត្តិការដែលសមស្របបំផុត សម្រាប់កិច្ចសហប្រតិបត្តិការអនុតំបន់ ដោយអនុលោមតាមលក្ខណៈពិសេសដោយឡែកជាក់លាក់នៃប្រទេសទាំងប្រាំមួយ(០៦)។ ការអនុវត្តផែនការសកម្មភាពនេះនឹងផ្អែកលើគោលការណ៍កុងសង់ស៊ីស សមភាព ការពិភាក្សា និងការសម្របសម្រួលគ្នាទៅមក ការស្ម័គ្រចិត្ត ការចូលរួមចំណែករួមគ្នា និងការចែករំលែកផលប្រយោជន៍ និងការគោរពធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ។ ឆ្នាំ២០១៨ និងឆ្នាំ២០១៩ នឹងជាដំណាក់កាលកសាងមូលដ្ឋានគ្រឹះ នៅពេលដែលការយកចិត្តទុកដាក់ គួរតែផ្តោតសំខាន់ទៅលើការធ្វើផែនការសហប្រតិបត្តិការតាមវិស័យ និងការអនុវត្តគម្រោងសហ-ប្រតិបត្តិការខ្នាតតូច និងមធ្យម។ ឆ្នាំ២០២០ ដល់ឆ្នាំ២០២២ នឹងជាដំណាក់កាលពង្រឹង និងពង្រីកបន្ថែម នៅពេលដែលប្រទេសជាសមាជិកនឹងពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ នៅក្នុងវិស័យអាទិភាពទាំងប្រាំ(០៥) និងអាចស្វែងរកវិស័យកិច្ចសហប្រតិបត្តិការថ្មីបន្ថែមទៀត ដែលជួយឆ្លើយតបទៅនឹងតម្រូវការ

អភិវឌ្ឍ របស់ប្រទេសសមាជិក បង្កើនប្រសិទ្ធភាពនៃទម្រង់គំរូកិច្ចសហប្រតិបត្តិការ និងស្វែងរកជាបណ្តើរៗនូវកិច្ចសហប្រតិបត្តិការលើគម្រោងខ្នាតធំ។

### III. រចនាសម្ព័ន្ធការងារ

៣. បង្កើនប្រសិទ្ធភាពក្របខ័ណ្ឌពហុកម្រិតរួមមាន កិច្ចប្រជុំកំពូល កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំឧត្តមមន្ត្រី និងកិច្ចប្រជុំក្រុមការងារ និងកិច្ចប្រជុំក្រុមការងាររួមតាមវិស័យ។

៤. ពង្រឹងទំនាក់ទំនង និងការសម្របសម្រួលក្នុងចំណោមលេខាធិការដ្ឋានជាតិ ឬអង្គភាពសម្របសម្រួលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនៃប្រទេសសមាជិកទាំងប្រាំមួយ(០៦) និងស្វែងរកលទ្ធភាពបង្កើតលេខាធិការដ្ឋានអន្តរជាតិនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៥. ដាក់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពនេះ ជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសតាមរយៈកិច្ចប្រជុំឧត្តមមន្ត្រីប្រចាំឆ្នាំ។ បញ្ជីគម្រោងដែលស្នើសុំដោយប្រទេសសមាជិកទាំងប្រាំមួយ(០៦) សម្រាប់ឆ្នាំបន្ទាប់ នឹងត្រូវដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសដើម្បីអនុម័ត។

៦. ផ្អែកលើកុងសង់ស៊ីសនៃប្រទេសសមាជិកទាំងប្រាំមួយ(០៦) បង្កើនឋានៈក្រុមការងាររួមតាមវិស័យអាទិភាពបន្តិចម្តងៗ ទៅកម្រិតឧត្តមមន្ត្រី ឬកម្រិតរដ្ឋមន្ត្រី។ ទន្ទឹមនឹងការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យអាទិភាព កិច្ចសហប្រតិបត្តិការក្នុងវិស័យផ្សេងទៀត ក៏ត្រូវបានលើកទឹកចិត្តផងដែរ។

៧. រចនានិមិត្តសញ្ញាកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងនិមិត្តសញ្ញាដទៃទៀតសម្រាប់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៨. បំពេញបន្ថែម និងអភិវឌ្ឍសហថាមភាពជាមួយយន្តការកិច្ចសហប្រតិបត្តិការអនុតំបន់មេគង្គដទៃទៀត។

៩. សម្របសម្រួលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន តាមរយៈការពិនិត្យលទ្ធភាពធ្វើទំនាក់ទំនងជាមួយគណៈកម្មាធិការសហប្រតិបត្តិការរួមអាស៊ាន-ចិន និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន និងស្ថាប័នអាស៊ានពាក់ព័ន្ធដទៃទៀត តាមកាលៈទេសៈជាក់ស្តែង។

### IV. កិច្ចសហប្រតិបត្តិការនយោបាយ

### ៤.១ បញ្ហានយោបាយ និងសន្តិសុខ

#### ៤.១.១ ថែរក្សាការផ្លាស់ប្តូរកម្រិតខ្ពស់

១០. រៀបចំកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងរៀងរាល់ពីរ(០២)ឆ្នាំម្តង ដើម្បីដាក់ចេញផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនាពេលអនាគត និងរៀបចំកិច្ចប្រជុំកំពូលវិសាមញ្ញតាមការចាំបាច់ ដោយផ្អែកលើកុងសង់ស៊ីស។

១១. រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមួយឆ្នាំម្តង ដើម្បីអនុវត្តសេចក្តីសម្រេចទាំងឡាយដែលសម្រេចបានដោយកុងសង់ស៊ីសនៅក្នុងកិច្ចប្រជុំកំពូល ពិនិត្យឡើងវិញនូវវឌ្ឍនភាពកិច្ចសហប្រតិបត្តិការ និងផ្តល់យោបល់សម្រាប់កិច្ចសហប្រតិបត្តិការ។

១២. រក្សាទំនាក់ទំនងជាទៀងទាត់ក្នុងចំណោមថ្នាក់ដឹកនាំនៃប្រទេសសមាជិកទាំងប្រាំមួយ(០៦) តាមរយៈទស្សនកិច្ចទ្វេភាគី ឬវេទិកាសហប្រតិបត្តិការអន្តរជាតិដទៃទៀត។

### ៤.១.២ ពង្រឹងកិច្ចសន្ទនានយោបាយ និងកិច្ចសហប្រតិបត្តិការ

១៣. រៀបចំកិច្ចប្រជុំឧត្តមមន្ត្រីការទូត និងកិច្ចប្រជុំក្រុមការងាររួមនៅក្នុងវិស័យការទូត និងវិស័យដទៃទៀត ជារៀងរាល់ឆ្នាំ តាមការចាំបាច់។

១៤. គាំទ្រកិច្ចសន្ទនាគោលនយោបាយ ការផ្លាស់ប្តូរ និងទស្សនកិច្ចផ្លូវការក្នុងចំណោមប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

### ៤.១.៣ ការផ្លាស់ប្តូរក្នុងចំណោមគណបក្សនយោបាយ

១៥. ជំរុញកិច្ចសន្ទនា និងការផ្លាស់ប្តូរក្នុងចំណោមគណបក្សនយោបាយនៃប្រទេសសមាជិកកិច្ចសហ-ប្រតិបត្តិការមេគង្គ-ឡានឆាង ដោយអនុលោមតាមស្មារតីនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

### ៤.១.៤ កិច្ចសហប្រតិបត្តិការសន្តិសុខមិនប្រពៃណី

១៦. ពង្រឹងកិច្ចសន្ទនាអនុវត្តច្បាប់និងកិច្ចសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការដោះស្រាយបញ្ហាសន្តិសុខមិនប្រពៃណីដោយផ្អែកលើផលប្រយោជន៍ទៅវិញទៅមក។

១៧. រួមគ្នាពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យបញ្ហាសន្តិសុខមិនប្រពៃណី ដូចជាការប្រយុទ្ធនឹងការជួញដូរគ្រឿងញៀន ភេរវកម្ម ការលួចឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ការជួញដូរមនុស្ស ការរត់ពន្ធ និងការជួញដូរអាវុធ និងគ្រាប់រំសេវ ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើនែត និងឧក្រិដ្ឋកម្មឆ្លងដែនដទៃទៀត។

១៨. ជំរុញការផ្លាស់ប្តូរក្នុងចំណោមរដ្ឋបាលមូលដ្ឋាន/តំបន់នៅតាមតំបន់ព្រំដែន និងអង្គភាពគ្រប់គ្រងព្រំដែននៃប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដោយអនុលោមតាមស្មារតីនៃកិច្ចសហ-ប្រតិបត្តិការមេគង្គ-ឡានឆាង និងច្បាប់ និងបទបញ្ញត្តិក្នុងស្រុកនៃប្រទេសសមាជិកនីមួយៗ។

១៩. ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមទីភ្នាក់ងារប៉ូលីស ស្ថាប័នតុលាការ មហាវិទ្យាល័យ និងសកលវិទ្យាល័យពាក់ព័ន្ធក្នុងចំណោមប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

២០. លើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យទប់ស្កាត់ និងកាត់បន្ថយគ្រោះមហន្តរាយ ជំនួយមនុស្សធម៌ ជានាសន្តិសុខស្បៀង ទឹក និងថាមពល។ ស្វែងរកដំណោះស្រាយនានា ដើម្បីគាំទ្រប្រជាជនទាំងឡាយ ដែលទទួលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

## ៤.២ សេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព

### ៤.២.១ ការតភ្ជាប់

២១. រៀបចំផែនការស្តីពីការតភ្ជាប់ តាមរយៈសហថាមភាពជាមួយផែនការមេ ស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងផែនការអនុតំបន់ផ្សេងទៀត ដើម្បីលើកកម្ពស់ការតភ្ជាប់គ្រប់ជ្រុងជ្រោយក្នុងចំណោមប្រទេសសមាជិក និងស្វែងរកលទ្ធភាពបង្កើតច្រករបៀងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

២២. ជំរុញការសាងសង់ និងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវដែក ផ្លូវហាយវ៉េ ផ្លូវទឹក កំពង់ផែ បណ្តាញអគ្គីសនី បណ្តាញព័ត៌មាន និងអាកាសចរណ៍។ លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធនាវាចរណ៍

ផ្កាយរណបសកល (global satellite navigation systems) រាប់ទាំងប្រព័ន្ធប៊ីឌូ (Beidou system) នៅ ក្នុងប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅក្នុងវិស័យដូចជា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូន ឡូជីស្ទីក ទេសចរណ៍ និងកសិកម្ម។

២៣. ជំរុញការសម្រួលការស្នើសុំទិដ្ឋាការ ការបំពេញបែបបទបញ្ចេញទំនិញពីគយ និងការដឹកជញ្ជូន និងការពិភាក្សាលើការអនុវត្តគំរូ "ច្រកចេញ-ចូលតែមួយ" សម្រាប់ការបំពេញបែបបទទំនិញឆ្លងកាត់ព្រំដែន។

២៤. លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការរៀបចំផែនការ ការសាងសង់ ការកែលម្អ និងការជួសជុលនិងការកែលម្អឡើងវិញដើម្បីជំរុញការតភ្ជាប់អគ្គីសនី និងពាណិជ្ជកម្មថាមពលក្នុងចំណោមប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឈានឆ្ពោះទៅការបង្កើតទីផ្សារថាមពលតំបន់រួមគ្នា។

២៥. រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍រលកអាកាស និងផែនការពាក់ព័ន្ធសម្រាប់ប្រទេសសមាជិកកិច្ចសហ-ប្រតិបត្តិការមេគង្គ-ឡានឆាង ជំរុញយ៉ាងសកម្មនូវការសាងសង់ និងការពង្រីកខ្សែកាបអុបទិកដីគោកឆ្លងកាត់ព្រំដែន និងខ្សែកាបបាតសមុទ្រអន្តរជាតិ។ ស្វែងរកគំរូសហប្រតិបត្តិការថ្មីសម្រាប់ខ្សែកាបអុបទិកដីគោកឆ្លងកាត់ព្រំដែនប្រទេសច្រើន បង្កើនការប្រើប្រាស់បណ្តាញតំបន់ដែលមានស្រាប់ និងធ្វើឱ្យប្រសើរឡើងជាប្រចាំនូវការតភ្ជាប់បណ្តាញក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង។

២៦. លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍនវានុវត្តន៍សម្រាប់ទូរទស្សន៍ឌីជីថល ស្មាតហ្វូន (smart phone) ផ្នែករឹងឆ្លាតវៃ (smart hardware) និងផលិតផលពាក់ព័ន្ធដទៃទៀត។

២៧. លើកកម្ពស់ការទទួលស្គាល់ស្តង់ដារ និងវិញ្ញាបនបត្រគ្នាទៅវិញទៅមក ចែករំលែកបទពិសោធន៍ការអភិវឌ្ឍពាក់ព័ន្ធ និងជំរុញកិច្ចសហប្រតិបត្តិការកសាងសមត្ថភាព។

### ៤.២.២ សមត្ថភាពផលិតកម្ម

២៨. រៀបចំផែនការសកម្មភាពស្តីពីកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតក្នុងចំណោមប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដោយអនុលោមតាមសេចក្តីប្រកាសរួមស្តីពីកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត ក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង។

២៩. លើកកម្ពស់ការកសាងសមត្ថភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផលិតករ និងអនុវត្តការផ្លាស់ប្តូរឧត្តមានុវត្តន៍ និងការបណ្តុះបណ្តាល។

៣០. ស្វែងរកលទ្ធភាពដើម្បីបង្កើតវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងការវិនិយោគ រៀបចំសកម្មភាពនានាដូចជា វេទិកាកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតកម្មសម្រាប់ប្រទេសមេគង្គ-ឡានឆាង និងស្វែងរកការបង្កើតសម្ព័ន្ធភាពសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងការវិនិយោគក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង។

៣១. លើកទឹកចិត្តសហគ្រាស និងស្ថាប័នហិរញ្ញវត្ថុនៃប្រទេសមេគង្គ-ឡានឆាង ដើម្បីចូលរួមក្នុងកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត។

៣២. ស្វែងរកការបង្កើតមូលនិធិអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសមត្ថភាពផលិតនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដោយមានការចូលរួមពហុភាគី។

### ៤.២.៣ សេដ្ឋកិច្ច និងពាណិជ្ជកម្ម

៣៣. ជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន តាមរយៈការកសាងតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែនគំរូ និងធ្វើការជាមួយគ្នាដើម្បីបង្កើនប្រសិទ្ធភាពក្របខ័ណ្ឌការងារកិច្ចសហប្រតិបត្តិការ និងការរៀបចំស្ថាប័ន និងយន្តការការងារ។

៣៤. លើកកម្ពស់ការសម្រួលពាណិជ្ជកម្ម និងវិនិយោគក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង និងធ្វើការកាត់បន្ថយរបាំងពាណិជ្ជកម្មមិនមែនពន្ធគយបន្ថែមទៀត។

៣៥. បង្កើតក្រុមប្រឹក្សាធុរកិច្ចមេគង្គ-ឡានឆាង។ ស្វែងរកការអភិវឌ្ឍសម្ព័ន្ធភាពសេវាកម្មសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។

៣៦. ពង្រឹងសកម្មភាពជំរុញពាណិជ្ជកម្មក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង រួមមាន ការរៀបចំពិព័រណ៌ពាណិជ្ជកម្មអន្តរជាតិ ការតាំងពិព័រណ៌ និងវេទិកាផ្គូរផ្គងធុរកិច្ច។

### ៤.២.៤ ហិរញ្ញវត្ថុ

៣៧. ធ្វើការជាមួយគ្នាដើម្បីកសាងប្រព័ន្ធហិរញ្ញវត្ថុមួយដែលមានពិពិធភាព ចីរភាព ស្ថិរភាព និងយូរអង្វែងក្នុងចំណោមប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដោយគិតគូរពីគោលការណ៍ ហិរញ្ញប្បទាននានាសម្រាប់កិច្ចសហប្រតិបត្តិការតំបន់ រួមទាំងគោលការណ៍ណែនាំស្តីពីហិរញ្ញប្បទានអភិវឌ្ឍន៍នៃខ្សែក្រវ៉ាត់ និងផ្លូវ។

៣៨. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរក្នុងចំណោមអាជ្ញាធរហិរញ្ញវត្ថុនៃប្រទេសមេគង្គ-ឡានឆាងដើម្បីទប់ស្កាត់ហានិភ័យហិរញ្ញវត្ថុ។

៣៩. បញ្ជាក់ពីសារៈសំខាន់នៃទីផ្សារហិរញ្ញវត្ថុមានស្ថិរភាព និងរចនាសម្ព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចពិត គាំទ្រកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនសមត្ថភាព និងការសម្របសម្រួលលើការគ្រប់គ្រងហិរញ្ញវត្ថុនិងលិខិតបទដ្ឋាន បន្តការសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ ដើម្បីសម្រួលដល់ការប្រើប្រាស់នៃការប្តូររូបិយប័ណ្ណទ្វេភាគី ការទូទាត់រូបិយប័ណ្ណក្នុងស្រុក និងកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ។

៤០. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័ននានាដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី សមាគមសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ី និងធនាគារពិភពលោក។

៤១. លើកទឹកចិត្តស្ថាប័នហិរញ្ញវត្ថុ ដើម្បីជួយសម្រួលប្រតិបត្តិការធុរកិច្ច ដើម្បីគាំទ្រពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងតំបន់។ បង្កើនការអភិវឌ្ឍផលិតផល និងសេវាកម្ម តាមរយៈអ្នកផ្តល់សេវា និងបណ្តាញនានា ដើម្បីលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងកំណើនប្រកបដោយចីរភាពនៅក្នុងតំបន់មេគង្គ-ឡានឆាង។

### ៤.២.៥ ធនធានទឹក

៤២. អនុវត្តគម្រោងការកម្រិតខ្ពស់សម្រាប់កិច្ចសហប្រតិបត្តិការធនធានទឹក ពង្រឹងកិច្ចសន្ទនាគោលនយោបាយស្តីពីធនធានទឹក និងរៀបចំវេទិកាកិច្ចសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង ជាប្រចាំ។

៤៣. ពន្លឿនការស្ថាបនាមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹកទន្លេមេគង្គ-ឡានឆាង ក្នុងគោលបំណងបង្កើតនូវវេទិកាកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង។

៤៤. ជំរុញកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការផ្លាស់ប្តូរ ស្តីពីការគ្រប់គ្រងធនធានទឹក ធ្វើការស្រាវជ្រាវ និងវិភាគរួមគ្នាពាក់ព័ន្ធនឹងធនធានទឹកមេគង្គ-ឡានឆាង និងឥទ្ធិពលនៃការប្រែប្រួល អាកាសធាតុ ។ល។ និងអនុវត្តគម្រោងសាកល្បង និងគម្រោងកិច្ចសហប្រតិបត្តិការអាទិភាពស្តីពីការ អភិវឌ្ឍធនធានទឹកប្រកបដោយចីរភាព និងបច្ចេកវិទ្យាការពារ។

៤៥. លើកកម្ពស់ និងជំរុញការកសាងសមត្ថភាពលើការគ្រប់គ្រងធនធានទឹក តាមរយៈការអនុវត្តកម្មវិធីសិក្សា កម្មវិធីនៃការផ្លាស់ប្តូរ ការបណ្តុះបណ្តាល ទស្សនកិច្ចដកស្រង់បទពិសោធន៍ (field trips) និងទស្សនកិច្ចសិក្សា ។

៤៦. អភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក ដែលប្រទេសមេគង្គ-ឡានឆាងទាំងអស់អាចប្រើប្រាស់បាន ពង្រឹងទិន្នន័យ និងការចែករំលែកព័ត៌មាន។

៤៧. ពង្រឹងការគ្រប់គ្រងបន្ទាន់នូវគ្រោះមហន្តរាយដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ទន្លេមេគង្គ-ឡានឆាង អនុវត្តការវាយតម្លៃរួមគ្នានៃការគ្រប់គ្រងទឹកជំនន់ និងការជួយសង្គ្រោះគ្រោះពេលរាំងស្ងួត និងសិក្សារួមគ្នាស្តីពីការបង្កើតឱ្យបានឆាប់នូវខ្សែទំនាក់ទំនង ដើម្បីចែករំលែកព័ត៌មានក្នុងករណីគ្រោះអាសន្ននៃទឹកជំនន់ និងគ្រោះរាំងស្ងួតនៅលើដងទន្លេមេគង្គ-ឡានឆាង។

៤៨. រៀបចំបង្កើតផែនការសកម្មភាពប្រាំឆ្នាំ ស្តីពីកិច្ចសហប្រតិបត្តិការធនធានទឹក ដែលបញ្ហានៃការព្រួយបារម្ភរួម នឹង ឬ អាចត្រូវបានដោះស្រាយ។

### ៤.២.៦ កសិកម្ម

៤៩. ពង្រឹងការសម្របសម្រួលគោលនយោបាយ និងពង្រឹងការសម្របសម្រួល ដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងសុវត្ថិភាពចំណីអាហារ ធ្វើឱ្យប្រសើរឡើងនូវឱកាសវិនិយោគ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព។

៥០. ពង្រីកការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្ម។ គាំទ្រស្ថាប័នស្រាវជ្រាវដើម្បីលើកកម្ពស់ការចែករំលែកព័ត៌មាន ទំនាក់ទំនង និងការផ្លាស់ប្តូរទស្សនកិច្ច។ កសាងមន្ទីរពិសោធន៍ មូលដ្ឋានសម្រាប់ការបង្ហាញ និងមជ្ឈមណ្ឌលបច្ចេកវិទ្យារួមគ្នា និងបង្កើតបណ្តាញព័ត៌មានកសិកម្មកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៥១. រៀបចំវេទិកាប្រធានភូមិក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង។

៥២. ពន្លឿនកិច្ចសហប្រតិបត្តិការគុណភាព និងសុវត្ថិភាពសម្រាប់ផលិតផលកសិកម្ម ជំរុញពាណិជ្ជកម្មផលិតផលកសិកម្ម បង្កើតទីផ្សារមេគង្គ-ឡានឆាងរួមសម្រាប់ផលិតផលកសិកម្ម និងលើកកម្ពស់ភាពប្រកួតប្រជែងនៃផលិតផលក្នុងតំបន់។

៥៣. អនុវត្តកិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យ ការព្រមានបឋម ការទប់ស្កាត់រួមគ្នា និងការគ្រប់គ្រងជំងឺសត្វ និងរុក្ខជាតិ និងស្ថានភាពជំងឺឆ្លង។ លើកកម្ពស់កិច្ចសហប្រតិបត្តិការខាងបសុពេទ្យ។ អនុវត្ត

សកម្មភាពអនុវត្តច្បាប់រួមគ្នាលើការគ្រប់គ្រងជលផល និងកិច្ចសហប្រតិបត្តិការលើការអភិរក្សធនធានទឹក។ បង្កើតយន្តការនៃការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការលើការអភិរក្សអេកូឡូស៊ីតាមដងទន្លេមេគង្គ-ឡានឆាង និងបង្កើតរួមគ្នានូវមជ្ឈមណ្ឌលសង្គ្រោះ និងបង្កាត់ពូជត្រីធម្មជាតិ (wild fish breeding) សម្រាប់ចែករំលែកព័ត៌មាន ឧទាហរណ៍ដូចជា ព័ត៌មានស្តីពីភាពចំរុះនៃត្រី ភាពសម្បូរបែបនៃត្រី និងការផ្លាស់ទីនៃត្រី ។ល។ ព្រមទាំងលទ្ធភាព និងឱកាសលើកិច្ចសហប្រតិបត្តិការជលផលដូចជា ការពង្រឹងការកសាងសមត្ថភាពក្នុងការអភិវឌ្ឍវារីវប្បកម្ម។

៥៤. ពិនិត្យលទ្ធភាពដើម្បីស្ថាបនារួមគ្នានូវសួនកសិ-ឧស្សាហកម្ម និងតម្រង់ទិសវិស័យមិនមែនរដ្ឋាភិបាលឱ្យចូលរួមក្នុងការសាងសង់ និងដំណើរការសួនទាំងនោះ។

### ៤.២.៧ ការកាត់បន្ថយភាពក្រីក្រ

៥៥. រៀបចំផែនការសកម្មភាពប្រាំឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ស្តីពីការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព និងពង្រឹងការផ្លាស់ប្តូរបទពិសោធន៍ និងការចែករំលែកចំណេះដឹងក្នុងចំណោមប្រទេសមេគង្គ-ឡានឆាង។

៥៦. លើកកម្ពស់កម្មវិធីកសាងសមត្ថភាពនានា និងការចែករំលែកបទពិសោធន៍លើការកាត់បន្ថយភាពក្រីក្រ រួមទាំងទស្សនវិជ្ជាសេដ្ឋកិច្ចគ្រប់គ្រាន់ (sufficiency economy philosophy-SEP) ដាក់ឱ្យដំណើរការនូវការផ្លាស់ប្តូរមន្ត្រីកម្រិតភូមិ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ប្រទេសមេគង្គ-ឡានឆាង។ ពង្រឹងសមត្ថភាពកាត់បន្ថយភាពក្រីក្រនៃប្រទេសមេគង្គ-ឡានឆាង តាមរយៈសកម្មភាពកសាងសមត្ថភាពពហុកម្រិត និងគ្រប់ទិដ្ឋភាពដូចជា ការផ្លាស់ប្តូរបុគ្គលិក ការប្រឹក្សាយោបល់គោលនយោបាយ ការស្រាវជ្រាវរួមគ្នា ការបណ្តុះបណ្តាល ការចែករំលែកព័ត៌មាន និងការគាំទ្របច្ចេកទេស។

៥៧. ដាក់ឱ្យដំណើរការគម្រោងសាកល្បងកាត់បន្ថយភាពក្រីក្រនៅបណ្តាប្រទេសមេគង្គ។

### ៤.២.៨ ព្រៃឈើ

៥៨. លើកកម្ពស់ការអភិរក្សនិងប្រើប្រាស់ធនធានព្រៃឈើ ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងរួមនៃប្រព័ន្ធអេកូព្រៃឈើតាមដងទន្លេមេគង្គ-ឡានឆាង។

៥៩. លើកកម្ពស់ទំហំពាណិជ្ជកម្មនៃផលិតផលព្រៃឈើ ដែលផលិតចេញពីវត្ថុធាតុដើមដែលទទួលបានស្របច្បាប់ លើកកម្ពស់ការអភិវឌ្ឍសហគ្រាសព្រៃឈើសហគមន៍ខ្នាតតូច ពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ចព្រៃឈើ លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងការកាប់ឈើខុសច្បាប់ និងពាណិជ្ជកម្មដែលពាក់ព័ន្ធ លើកកម្ពស់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការផ្លាស់ប្តូរនៅក្នុងវិស័យព្រៃឈើ ព្រមទាំងលើកកម្ពស់ការស្តារព្រៃឈើឡើងវិញ និងការដាំដើមឈើនៅតាមដងទន្លេមេគង្គ។

៦០. បង្កើនកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃនៅតាមតំបន់ព្រំដែន។

៦១. បង្កើនកិច្ចសហប្រតិបត្តិការអភិរក្សសត្វព្រៃ និងរួមគ្នាប្រយុទ្ធប្រឆាំងនឹងការជួញដូរសត្វព្រៃខុសច្បាប់។

៦២. បង្កើនការកសាងសមត្ថភាពប្រទេសមេគង្គ-ឡានឆាងក្នុងការគ្រប់គ្រងព្រៃឈើ និងស្រាវជ្រាវវិទ្យាសាស្ត្រ លើកកម្ពស់កិច្ចសហប្រតិបត្តិការធនធានមនុស្ស និងការអប់រំកម្រិតខ្ពស់ពាក់ព័ន្ធនឹងព្រៃឈើ អនុ

វត្តការបណ្តុះបណ្តាលតាមប្រធានបទ និងអនុវត្តគម្រោងអាហារូបករណ៍ និងគម្រោងទស្សនកិច្ចសិក្សារបស់អ្នកស្រាវជ្រាវ។

### ៤.២.៩ ការការពារបរិស្ថាន

៦៣. ជំរុញការបង្កើតមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការបរិស្ថានមេគង្គ-ឡានឆាង។ ធ្វើសហថាមភាពផែនការអភិរក្សការពារបរិស្ថាននៃប្រទេសមេគង្គ-ឡានឆាង និងបង្កើតយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការបរិស្ថានមេគង្គ-ឡានឆាង។

៦៤. រៀបចំ និងអនុវត្តផែនការមេគង្គ-ឡានឆាងបៃតង ដោយផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងការបំពុលខ្យល់ និងទឹក ក៏ដូចជាការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី និងលើកកម្ពស់ទំនាក់ទំនងជាមួយយន្តការអនុតំបន់ពាក់ព័ន្ធដទៃទៀត។

៦៥. ពង្រឹងកិច្ចសហប្រតិបត្តិការលើការកសាងសមត្ថភាពការពារបរិស្ថាន ការផ្សព្វផ្សាយ និងការអប់រំព្រមទាំងលើកកម្ពស់ការយល់ដឹងពីបរិស្ថានជាសាធារណៈ។

### ៤.២.១០ អធិការកិច្ចគយ និងគុណភាព

៦៦. ពិនិត្យលទ្ធភាពបង្កើតផែនការសហប្រតិបត្តិការ និងជំរុញឱ្យមានការរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់នៅក្នុងចំណោមអង្គភាពអធិការកិច្ចគយ និងគុណភាពនៃប្រទេសទាំងប្រាំមួយ(០៦)។

៦៧. បង្កើនល្បឿននៃការបំពេញបែបបទបញ្ចេញទំនិញ ជាពិសេសផលិតផលកសិកម្ម។

៦៨. លើកកម្ពស់ស្តង់ដារផលិតផល ជំរុញការបណ្តុះបណ្តាល កិច្ចសហប្រតិបត្តិការ និងការទទួលស្គាល់គ្នាទៅវិញទៅមកលើវិញ្ញាបនប័ត្រ និងការទទួលស្គាល់ជាផ្លូវការ។ អនុវត្តជំនួយវិស័យមាត្រាសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវការកសាងសមត្ថភាពមាត្រាសាស្ត្រនៅក្នុងប្រទេសមេគង្គ-ឡានឆាង។

## ៤.៣ កិច្ចសហប្រតិបត្តិការសង្គម និងវប្បធម៌

### ៤.៣.១ វប្បធម៌

៦៩. ចែករំលែកព័ត៌មានអំពីគោលនយោបាយពាក់ព័ន្ធនឹងវប្បធម៌។ លើកកម្ពស់កិច្ចសន្ទនាវប្បធម៌ និងធ្វើការដើម្បីអនុវត្តគំនិតផ្តួចផ្តើមនីងបូ (Ningbo Initiative) ស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌មេគង្គ-ឡានឆាង។

៧០. បង្កើនការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ និងសិល្បៈ ការអភិរក្សវប្បធម៌វត្ថុបុរាណ ការថែរក្សាបេតិកភណ្ឌវប្បធម៌អរូបី ឧស្សាហកម្មវប្បធម៌ និងការអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យវប្បធម៌ និងលើកទឹកចិត្តឱ្យមានអន្តរកម្ម និងកិច្ចសហការក្នុងចំណោមស្ថាប័នវប្បធម៌ ក្រុមហ៊ុនសិល្បៈ និងសហគ្រាសវប្បធម៌។

៧១. ប្រើប្រាស់យ៉ាងពេញលេញនូវមជ្ឈមណ្ឌលវប្បធម៌ចិននៅតាមបណ្តាប្រទេសមេគង្គ ដើម្បីរៀបចំសកម្មភាពវប្បធម៌នានា ក្នុងចំណោមប្រទេសសមាជិកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

### ៤.៣.២ ទេសចរណ៍

៧២. ពិនិត្យលទ្ធភាពបង្កើតសម្ព័ន្ធភាពកិច្ចសហប្រតិបត្តិការទីក្រុងទេសចរណ៍មេគង្គ-ឡានឆាង។

៧៣. ជំរុញការបណ្តុះបណ្តាលមគ្គុទេសទេសចរណ៍ និងលើកទឹកចិត្តបណ្តាប្រទេសមេគង្គ-ឡានឆាង ឱ្យចូលរួមក្នុងសកម្មភាព និងព្រឹត្តិការណ៍ទេសចរណ៍ពាក់ព័ន្ធ ដូចជាវេទិកាទេសចរណ៍អាស៊ាន វេទិកាទេសចរណ៍មេគង្គ និងទីផ្សារទេសចរណ៍អន្តរជាតិចិន (CITM)។

៧៤. ពិនិត្យលទ្ធភាពក្នុងការបង្កើតទស្សនវិស័យអភិវឌ្ឍន៍ទេសចរណ៍រយៈពេលមធ្យម/រយៈពេលវែង របស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ទាំងរឹង និងទន់។

៧៥. បង្កើនការទទួលស្គាល់ស្តីពីការជំរុញស្តង់ដារទេសចរណ៍អាស៊ាន។

### ៤.៣.៣ ការអប់រំ

៧៦. ជំរុញសកម្មភាពនានាដើម្បីលើកកម្ពស់កិច្ចសហការក្នុងចំណោមបណ្តាប្រទេសមេគង្គ-ឡានឆាង នាអំឡុងពេលសប្តាហ៍នៃកិច្ចសហប្រតិបត្តិការអប់រំអាស៊ាន-ចិន។

៧៧. ពង្រឹងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រដល់ការបង្កើតមូលដ្ឋានអប់រំវិជ្ជាជីវៈមេគង្គ-ឡានឆាងនៅក្នុងប្រទេសចិន ក៏ដូចជាមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈមេគង្គ-ឡានឆាងនៅតាមបណ្តាប្រទេសមេគង្គ។

៧៨. ជំរុញកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ និងមហាវិទ្យាល័យនៅតំបន់មេគង្គ-ឡានឆាង លើកទឹកចិត្តឱ្យមានកម្មវិធីស្រាវជ្រាវនិងបណ្តុះបណ្តាលរួមគ្នា ការផ្លាស់ប្តូរការសិក្សានិងស្វែងរកការទទួលស្គាល់ និងផ្ទេរក្រេឌីតពិន្ទុ។

### ៤.៣.៤ សុខាភិបាល

៧៩. ពង្រឹងកិច្ចសហប្រតិបត្តិការលើការទប់ស្កាត់ និងគ្រប់គ្រងជំងឺឆ្លងដែលលេចឡើង និងជំងឺឆ្លងដែលលេចឡើងសាជាថ្មីដូចជា ជំងឺគ្រុនឈាម និងជំងឺគ្រុនចាញ់។ បង្កើត និងកែលម្អយន្តការសម្រាប់ការព្រមានបឋម ការឃ្លាំមើលរួមគ្នា ការទប់ស្កាត់ និងគ្រប់គ្រងជំងឺឆ្លងដែលលេចឡើង និងជំងឺឆ្លងដែលលេចឡើងសាជាថ្មី ឆ្លងកាត់ព្រំដែន។

៨០. លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមមន្ទីរពេទ្យ និងគ្រឹះស្ថានសុខាភិបាល ដើម្បីសម្របសម្រួលការផ្លាស់ប្តូរបច្ចេកទេស និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល។ ពន្លឿនកិច្ចសហប្រតិបត្តិការក្នុងការសាងសង់មន្ទីរពេទ្យនៅតាមជនបទ ក្នុងចំណោមប្រទេសសមាជិកទាំងប្រាំមួយ(០៦)។

៨១. ផ្តល់សេវាពិគ្រោះវេជ្ជសាស្ត្ររយៈពេលខ្លីដូចជា សកម្មភាពភ្លឺថ្លា (Brightness Action) សកម្មភាពស្នាមញញឹម (Smile Action) (ការព្យាបាលវេជ្ជសាស្ត្រលើផ្ទៃមុខដែលខុសទម្រង់) និងសេវាវេជ្ជសាស្ត្រសម្រាប់ស្ត្រី និងកុមារដោយឥតគិតថ្លៃ។ ចិននឹងបញ្ជូនក្រុមគ្រូពេទ្យទៅកាន់ប្រទេសនៅតាមដងទន្លេមេគង្គដែលត្រូវការជំនួយ។

### ៤.៣.៥ ប្រព័ន្ធផ្សព្វផ្សាយ

៨២. ពង្រឹងការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តាញផ្សព្វផ្សាយព័ត៌មាន និងលើកទឹកចិត្តឱ្យមានរៀបចំកម្មវិធីទូរទស្សន៍ និងពិធីចាក់បញ្ចាំងខ្សែភាពយន្ត ឬសកម្មភាពបញ្ចាំងផ្សេងៗទៀត។

៨៣. លើកទឹកចិត្តក្រសួងការបរទេសនៃប្រទេសទាំងប្រាំមួយ(០៦) ឱ្យបង្កើតគេហទំព័រផ្លូវការរបស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឬឱ្យផ្តល់ព័ត៌មានផ្លូវការអំពីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅលើគេហទំព័ររបស់ខ្លួន។ ប្រើប្រាស់វេទិកាប្រព័ន្ធទំនាក់ទំនងសង្គមជាវេទិកាមូលដ្ឋាន ដើម្បីផ្សព្វផ្សាយព័ត៌មាន និងដោះស្រាយកិច្ចការសាធារណៈដែលចាត់ទុកថាសមស្រប។

៨៤. ដាក់ឱ្យដំណើរការទស្សនាវដ្តី ឬ ខិត្តប័ណ្ណព័ត៌មានមេគង្គ-ឡានឆាង និងបង្កើតមូលដ្ឋានទិន្នន័យសម្រាប់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ។

### ៤.៣.៦ ការផ្លាស់ប្តូរប្រជាជន-ប្រជាជន និងកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់មូលដ្ឋាន/តំបន់

៨៥. តាមរយៈការរៀបចំសកម្មភាពប្រជាជននិងប្រជាជន លើកកម្ពស់កិត្តិនាមកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងបង្កើនការយល់ដឹងជាសាធារណៈអំពីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនៅក្នុងប្រទេសប្រាំមួយ(០៦)។

៨៦. ជំរុញការផ្លាស់ប្តូរយុវជន និងរៀបចំគម្រោងផ្លាស់ប្តូរយុវជនសំខាន់ៗ ក្នុងចំណោមប្រទេស មេគង្គ-ឡានឆាង។

៨៧. លើកកម្ពស់សមភាពយេនឌ័រ ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការស្ត្រី តាមរយៈការបង្កើតសកម្មភាពនានា រួមទាំងវគ្គបណ្តុះបណ្តាល និងការផ្លាស់ប្តូរទស្សនកិច្ច។

៨៨. ប្រមែប្រមូលរដ្ឋបាលថ្នាក់មូលដ្ឋាន/តំបន់នៃប្រទេសទាំងប្រាំមួយ(០៦) ចូលរួមក្នុងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងលើកទឹកចិត្តឱ្យមានការចូលរួមរបស់រដ្ឋបាលទាំងនោះនៅក្នុងគម្រោង។

៨៩. លើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមក្នុងគម្រោងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងតាមកាលៈទេសៈសមស្រប។

៩០. ពង្រឹងការផ្លាស់ប្តូរក្នុងចំណោមសង្គមកាកបាទក្រហម (Red Cross Societies) បង្កើតកម្មវិធីភាពធន់របស់សហគមន៍ និងលើកកម្ពស់ការកសាងសមត្ថភាពសង្គមកាកបាទក្រហមនៅក្នុងប្រទេសមេគង្គ-ឡានឆាង។

៩១. លើកទឹកចិត្តឱ្យមានទស្សនកិច្ចសិក្សាបុគ្គលិក និងការទំនាក់ទំនង ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការ ស្តីពីការគ្រប់គ្រងរបស់រដ្ឋលើកិច្ចការសាសនា និងអន្តរសាសនាតាមការគួររបស់ប្រទេសសមាជិក។

## V. ប្រព័ន្ធគាំទ្រ

### ៥.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុ

៩២. ប្រើប្រាស់យ៉ាងពេញលេញនូវមូលនិធិពិសេសកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលបង្កើតឡើងដោយចិន។ គាំទ្រគម្រោងអាទិភាពដែលត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូល ឬកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស និងអនុលោមតាមគោលដៅដែលបានកំណត់ដោយសេចក្តីថ្លែងការណ៍ទីក្រុងសានយ៉ា និងឯកសារសំខាន់ៗផ្សេងទៀត ដែលបានឯកភាពដោយថ្នាក់ដឹកនាំ និងរដ្ឋមន្ត្រីការបរទេស។ លើកទឹកចិត្តឱ្យមានការផ្តល់ធនធានហិរញ្ញវត្ថុ និងធនធានបន្ថែមទៀតពីប្រទេសទាំងប្រាំមួយ(០៦)។ ស្វែងរកការគាំទ្រយ៉ាងសកម្មពីស្ថាប័នហិរញ្ញវត្ថុ

ដូចជា ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី មូលនិធិផ្លូវសូត្រ និងធនាគារអភិវឌ្ឍន៍អាស៊ី។ បង្កើនធនធានសង្គម និងទីផ្សារ ព្រមទាំងបង្កើតប្រព័ន្ធគាំទ្រហិរញ្ញវត្ថុពេញលេញមួយ។

## ៥.២ ការគាំទ្រផ្នែកបញ្ញាស្មារតី

៩៣. ស្វែងរកគំរូកិច្ចសហប្រតិបត្តិការដែលរួមបញ្ចូលរដ្ឋាភិបាល វិស័យឯកជន និងគ្រឹះស្ថានសិក្សា ដើម្បីឱ្យធ្វើការរួមគ្នាលើការបង្កើតមជ្ឈមណ្ឌលសកលសម្រាប់ការសិក្សាទន្លេមេគង្គ និងបង្កើតក្រុម Track II និងបណ្ដាញនៃវិទ្យាស្ថានស្រាវជ្រាវ និងវិភាគ (think-tank) នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

## ៥.៣ យន្តការត្រួតពិនិត្យ

៩៤. ប្រើប្រាស់លេខាធិការដ្ឋានជាតិ ឬអង្គភាពសម្របសម្រួលកិច្ចសហប្រតិបត្តិការមេគង្គឡានឆាងនៃប្រទេសទាំងប្រាំមួយ(០៦)។ ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា និងសម្របសម្រួលធនធាននានា ដើម្បីបង្កើតឱ្យមានសហថាមភាព។ ត្រួតពិនិត្យ និងផ្តល់យោបល់ដល់អង្គភាព/ទីភ្នាក់ងារពាក់ព័ន្ធនៃប្រទេសរបស់ខ្លួន ដើម្បីចូលរួមក្នុងកិច្ចសហប្រតិបត្តិការ និងធ្វើការវាយតម្លៃជាទៀងទាត់ លើសកម្មភាពសំខាន់ៗ។ ប្រើប្រាស់ធនធានរបស់ស្ថាប័នវិជ្ជាជីវៈមិនមែនរដ្ឋាភិបាល ដែលអាចដើរតួជាអ្នកត្រួតពិនិត្យភាគីទីបី។

------------------------